## ព្រះរាជក្រម ជស/រកត/១១៩៧/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរំលូតកូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពីការរំលូតកូន

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១.**– ច្បាប់នេះមានគោលដៅកំណត់ពីបែបបទ និងលក្ខខ័ណ្ឌនៃការរំលូតកូន ។

**មាត្រា២.**– ការរំលូតកូនគឺជាការបញ្ចប់គភ៌តាមវិធីវេជ្ជសាស្ត្រ ឬតាមវិធីណាមួយ ។

**មាត្រា៣.**– ស្ត្រីមានគភ៌ទាំងឡាយអាចសុំអោយគ្រូពេទ្យធ្វើការរំលូតកូនបាន ក្រោយពីបានបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា៤.**– ក្នុងករណីណាក៏ដោយ ការរំលូតកូនត្រូវតែមានសំណូមពរនិងបានទទួលការយល់ព្រមពីស្ត្រីដែលមានគភ៌ ។

**មាត្រា៥.**– មានតែវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ទើបអាចធ្វើការរំលូតកូនបាន ។

### ជំពូកទី

### បែបបទ និងលក្ខខ័ណ្ឌ

**មាត្រា៦.**– ការរំលូតកូនប្រព្រឹត្តទៅបានតែនៅក្នុងមន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក មន្ទីរសម្ភពសាធារណៈឬឯកជនដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។ រាល់សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូនត្រូវមាន :

- លទ្ធភាពបច្ចេកទេសព្យាបាលបន្ទាន់នូវរាល់ផលវិបាកនៃការរំលូតកូន
- មធ្យោបាយបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើមានការចាំបាច់

**មាត្រា៧.**– វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលមានភារកិច្ចធ្វើការរំលូតកូន ត្រូវពន្យល់ណែនាំដល់ស្ត្រីដែលមានគភ៌មកសុំធ្វើការរំលូតកូន គឺគ្រោះថ្នាក់ដែលអាចកើតមានឡើង

ជាយថាហេតុបណ្តាលមកពីការរំលូតកូននេះនិងពីផលប្រយោជន៍នៃកិច្ចពន្យារកំណើត។

ប្រសិនបើស្ត្រីដែលមានគភ៌នោះ នៅតែទទូចសុំធ្វើការរំលូតកូន វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមអាចធ្វើការរំលូតកូនបាន តែត្រូវស្ថិតក្នុងល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា៨.**–ការរំលូតកូនអាចធ្វើទៅបានចំពោះតែគភ៌ណាដែលមានអាយុតិចជាង ១២ សប្តាហ៍ ។ លើសពី ១២ សប្តាហ៍នៃអាយុគភ៌ ការរំលូតកូនអាចទទួលការអនុញ្ញាតបាន លុះតែក្នុងពេលធ្វើរោគវិនិច្ឆ័យឃើញថា :

–គភ៌នោះមានភវនីយភាពមិនលូតលាស់ដូចប្រក្រតី ឬបង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ

–កូនដែលនឹងកើតមកអាចជម្ងឺធ្ងន់ធ្ងរព្យាបាលពុំជា

–ក្នុងករណីដែលត្រូវគេរំលោភបណ្តាលអោយមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបានដោយមានគិតពីល័ក្ខខ័ណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមានអាយុ ១៨ ឆ្នាំឡើងទៅ ឬការស្នើសុំដោយទទួចពីឪពុកម្តាយ ឬ អាណាព្យាបាល និងសាមីខ្លួន បើស្ត្រីដែលមានគភ៌មានអាយុតិចជាង ១៨ឆ្នាំ ។

ការសំរេចនៃបញ្ហានេះ ត្រូវមានការឯកភាពពីក្រុមគ្រូសារ ២ ឬ ៣រូប រួមទាំងសាមីខ្លួនផង ។ ល័ក្ខខ័ណ្ឌបច្ចេកទេសសម្រាប់ការអនុវត្តន៍នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា៩.**–រាល់ឯកសារដែលមានទាក់ទងទៅនឹងការរំលូតកូន ត្រូវរក្សាទុកជាការសម្ងាត់ ហើយអាចផ្តល់ទៅសាមីខ្លួន ឬតុលាការប្រសិនបើមានការស្នើសុំជាលាយល័ក្ខអក្សរ ។

**មាត្រា១០.**–សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូនដូចមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវរៀបចំឯកសារច្បាស់លាស់ ស្តីពីករណីរំលូតកូននីមួយៗ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រសួងសុខាភិបាលដោយទៀងទាត់នូវចំនួនរំលូតកូន និងមធ្យោបាយរំលូត ។

## ជំពូកទី ៣

## សមត្ថកិច្ចត្រួតពិនិត្យ

**មាត្រា១១.**_ការត្រួតពិនិត្យការរំលូតកូនតាមការកំណត់នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៤

## ទោសប្បញ្ញត្តិ

**មាត្រា១២.**_ជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ ឬ ៦ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្ម និងទោសទណ្ឌដូចខាងក្រោម :

_បើជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវព្រមាន ។ ក្នុងករណីមិនរាងចាលត្រូវបញ្ឈប់ពីមុខងារឬបិទគ្លីនិកឬមន្ទីរសម្ភពនោះ ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដូចចែងខាងក្រោមនេះ ។

_បើមិនមែនជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ឆ្នាំ ។

_បើការរំលូតកូននោះបណ្តាលអោយស្ត្រីដែលមានគភ៌មានជម្ងឺរ៉ាំរ៉ៃឬពិការ ត្រូវផ្តន្ទាទោសពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

_បើការរំលូតកូនបណ្តាលអោយស្ត្រីដែលមានគភ៌មានគ្រោះថ្នាក់ដល់ស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

**មាត្រា១៣.**_វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតអោយធ្វើការរំលូតកូន ហើយមិនគោរពលក្ខខណ្ឌណាមួយដូចចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវដកហូតយកលិខិតអនុញ្ញាតដែលចេញអោយដោយក្រសួងសុខាភិបាល ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

លើកលែងតែក្នុងករណីធ្ងន់ធ្ងរដែលស្ត្រីមានគភ៌ត្រូវសង្គ្រោះបន្ទាន់ វិធីវេជ្ជសាស្ត្រនឹងត្រូវបានជានាំចំពោះមុខច្បាប់ ។

**មាត្រា១៤.**_ជនទាំងឡាយណា ដែលបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។ បើការបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនានោះ បណ្តាលអោយស្ត្រីដែលមានគភ៌មានជម្ងឺពិការ ពិការឬបណ្តាលអោយស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

**មាត្រា១៥.**_ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

_បើជាមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មតាមមាត្រា ៤០ និង ៤១ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

_បើមិនមែនជាមន្ត្រីរាជការ ត្រូវបិទគ្លីនិក ឬមន្ទីរសម្ភពឯកជនពី ១ខែ ទៅ ៣ខែ ឬពិន័យជាប្រាក់ពី ប្រាំលានរៀល (៥.០០០.០០០) ដល់ដប់លានរៀល (១០.០០០.០០០) ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១៦.**_បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា
**អ៊ឹម ហួត ហ៊ុន សែន**

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង
សម្តេច នាយករដ្ឋមន្ត្រីទី២
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
ហត្ថលេខា
**ឈា ថាំង**